## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋបាលជលផល

# ឯកសារបណ្តុះបណ្តាលស្តីពីសហគ្រប់គ្រងធនធានជលផល

*គម្រោងគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ ដំណាក់កាលទី៣ (M-IWRMP-III)*

*សមាសភាគទី១៖ ការគាំទ្រដល់ការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា*

***វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល***
***២០១៨***

# សហគ្រប់គ្រងធនធានជលផល
# ឯកសារទី១ : ការបង្កើតសហគមន៍នេសាទ



គម្រោងគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ ដំណាក់កាលទី៣ ( M-IWRMP-III )

សមាសភាគទី១៖ ការគាំទ្រដល់ការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប នៃរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ១. តើសហគ្រប់គ្រងធនធានជលផលមានន័យដូចម្ដេច?

សហគ្រប់គ្រង សំដៅដល់ភាពជាដៃគូរវាង សហគមន៍នេសាទ ស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត (ដូចជា៖ អ្នកលក់ត្រី អ្នកជំនួញ អង្គការមិនមែនរដ្ឋាភិបាល ។ល។) និងបែងចែកសិទ្ធិរួមទាំងការទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានជលផល។

ចំពោះកិច្ចសហការរវាងស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល និងប្រជានេសាទនៅមូលដ្ឋាន ចាំបាច់ត្រូវបង្កើតសហគមន៍នេសាទ។

តាមរយៈកិច្ចពិគ្រោះយោបល់ និងការចរចារដ្ឋបាលជលផល និងសហគមន៍នេសាទត្រូវបង្កើតកិច្ចព្រមព្រៀងដូចជា៖ កន្លែងនេសាទ សហគមន៍ តួនាទី និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ និងសិទ្ធិក្នុងការគ្រប់គ្រងធនធានជលផល។



## ១. តើសហគ្រប់គ្រងធនធានជលផលមានន័យដូចម្តេច? (ត)

សហគ្រប់គ្រងធនធានជលផលរួមមាន៖

- សមាជិកភាពប្រកបដោយសមធម៌៖ យុត្តិធម៌ ស្មើភាព និងបើកទូលាយចំពោះប្រជាពលរដ្ឋទូទៅ (ស្ត្រីត្រូវបានលើកទឹកចិត្ត ឱ្យចូលជាសមាជិកសហគមន៍នេសាទ)
- រួបរួមគ្នា និងសហប្រតិបត្តិការ៖ ធ្វើការជាមួយអ្នកណាម្នាក់ ដើម្បីផលិតអ្វីមួយ
- បែងចែកសិទ្ធិអំណាច(ការទទួលខុសត្រូវ និងសិទ្ធិអំណាច)៖ ទទួលខុសត្រូវរួមគ្នា លើការសម្រេចចិត្ត
- មានគោលដៅច្បាស់លាស់
- កិច្ចព្រមព្រៀង៖ ការរៀបចំរវាងភាគីពាក់ព័ន្ធចំពោះសកម្មភាពជាក់លាក់។



## ២. គោលការណ៍គ្រប់គ្រងធនធានជលផលតាមបែបប្រព័ន្ធអេកូឡូស៊ី

**សហគ្រប់គ្រងធនធានជលផលដែលល្អរួមមាន៖** តុល្យភាពរវាងសមាសធាតុចំនួនបីគឺបរិស្ថានល្អ សុខុមាលភាពប្រជាពលរដ្ឋ និងអភិបាលកិច្ចល្អ

- បរិស្ថានល្អ៖ មានពូជត្រីគ្រប់ប្រភេទ ផលត្រីសម្បូរ មិនធ្វើឱ្យខូចខាតជម្រកត្រី និងទឹកមានគុណភាព

- សុខុមាលភាពប្រជាពលរដ្ឋ៖ មានស្តង់ដាររស់នៅល្អ (ប្រាក់ចំណូលសមរម្យ) សុវត្ថិភាពស្បៀង ទំនាក់ទំនងសង្គមមានភាពប្រសើរឡើង និងធានាសុវត្ថិភាព

- អភិបាលកិច្ចល្អ៖ សំដៅដល់ការចូលរួម សិទ្ធិជាផ្លូវការ សមធម៌ យន្តការរៀបចំផែនការនិងការអនុវត្ត ការគោរព និងពង្រឹងការអនុវត្តន៍ច្បាប់។

វាជាអភិក្រម (វិធីសាស្ត្រ)មួយ ដែលគិតគូរទៅលើធាតុសំខាន់ៗនៅក្នុងប្រព័ន្ធអេកូឡូស៊ី និងគិតគូរពីផលប្រយោជន៍សេដ្ឋកិច្ចសង្គមបានមកតាមរយៈការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។



## ៣. តើសហគមន៍នេសាទមានន័យដូចម្តេច ?

**សហគមន៍នេសាទគឺជា៖**

- ក្រុមរូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ
- ចូលរួមជាសមាជិកសហគមន៍នេសាទដោយស្ម័គ្រចិត្ត ដែលរស់នៅក្នុង ឬក្បែរដែននេសាទ
- មានគំនិតផ្តួចផ្តើម កែលម្អគុណភាពជីវិតដោយប្រើប្រាស់ និងកែច្នៃធនធានជលផលប្រកបដោយនិរន្តរភាព។

សហគមន៍នេសាទតំណាងឱ្យប្រជាពលរដ្ឋកម្ពុជា ក្នុងភាពជាដៃគូជាមួយនឹងស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល ដែលមានរដ្ឋបាលជលផលជាតំណាង។

រដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវការសហការរៀបចំសហគមន៍នេសាទ។



## ៤. តួនាទី និងការទទួលខុសត្រូវរបស់ប្រជានេសាទនៅក្នុងសហគមន៍នេសាទ

**សមាជិកនៃសហគមន៍នេសាទមួយមានសិទ្ធិក្នុងការ៖**

- នេសាទជាលក្ខណៈគ្រួសារ ដោយគោរពតាមច្បាប់ និងលិខិតបទដ្ឋានដែលទាក់ទងទៅនឹងវិស័យជលផល និងលក្ខន្តិកៈរបស់សហគមន៍
- ចូលរួមគ្រប់សកម្មភាពរបស់សហគមន៍នេសាទ
- ស្នើឱ្យមានកិច្ចប្រជុំ និងលើកឡើងនូវបញ្ហាទាក់ទងនឹងជលផល និងពិភាក្សារកដំណោះស្រាយ
- តវ៉ាចំពោះបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍សហគមន៍នេសាទ ទៅក្រុមប្រឹក្សា ឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន ឬរដ្ឋបាលជលផល និងសមត្ថកិច្ចពាក់ព័ន្ធនានា
- ចូលរួមប្រជុំបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតក្នុងគណៈកម្មការសហគមន៍នេសាទ។









## ៥. ជំហានទាំង៩ នៃការបង្កើតសហគមន៍នេសាទ

*ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទបានកំណត់ជំហានទាំង៩ រួមមាន៖*

- ការបង្កើតក្រុមស្ថាបនិក និងដាក់ពាក្យស្នើសុំបង្កើតសហគមន៍នេសាទ
- ការសិក្សាលទ្ធភាពបង្កើតសហគមន៍នេសាទ
- ការចុះឈ្មោះសមាជិកសហគមន៍
- ការរៀបចំចក្ខុវិស័យ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- ការរៀបចំផែនទីកន្លែងនេសាទសហគមន៍
- ការរៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ការចុះបញ្ជីសហគមន៍នេសាទ
- ការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។



## ៥.១ ជំហានទី១៖ ការបង្កើតក្រុមស្ថាបនិក

សហគមន៍មូលដ្ឋានដែលមានបំណងបង្កើតសហគមន៍នេសាទត្រូវបង្កើតក្រុមស្ថាបនិកជាមុន។



ក្រុមស្ត្រី ជនជាតិដើមភាគតិច ក្រុមភាគតិចគួរត្រូវបានបញ្ចូលក្នុងក្រុមស្ថាបនិក។

ក្រុមស្ថាបនិកផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋក្នុងភូមិ អំពីផលប្រយោជន៍នៃការបង្កើតសហគមន៍នេសាទ បន្ទាប់មកដាក់សំណើទៅខណ្ឌរដ្ឋបាលជលផល ដើម្បីជួយសម្របសម្រួលបង្កើតសហគមន៍។

## ៥.២ ជំហានទី២ ៖ ការវាយតម្លៃអំពីលទ្ធភាពបង្កើតសហគមន៍នេសាទ

បន្ទាប់ពីបានដាក់សំណើសុំបង្កើតសហគមន៍នេសាទ ក្រុមស្ថាបនិក ដោយមានការគាំទ្របច្ចេកទេស ពីខណ្ឌរដ្ឋបាលជលផលត្រូវរៀបចំសិក្សាវាយតម្លៃ និងប្រមូលព័ត៌មានដាក់លាក់ទាក់ទងនឹង៖

- ស្ថានភាពសេដ្ឋកិច្ចសង្គម
- ស្ថានភាពនេសាទ
- ស្ថានភាពដែននេសាទ
- សកម្មភាពនានាទាក់ទងទៅ នឹងការនេសាទ
- ស្ថានភាពទាក់ទង នឹងកសិកម្ម
- បញ្ហាកើតឡើងក្នុងសហគមន៍នេសាទដែលទាក់ទងទៅនឹងវិស័យជលផល។



## ៥.៣ ជំហានទី៣៖ ការចុះឈ្មោះសមាជិកសហគមន៍នេសាទ

ក្រុមស្ថាបនិកមានភារកិច្ច ចុះឈ្មោះប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចូលជាសមាជិកសហគមន៍នេសាទ។ ក្រុមស្ត្រីត្រូវបានលើកទឹកចិត្តឱ្យចូលរួមជា សមាជិកសហគមន៍នេសាទ។ ដោយមានការសម្របសម្រួលពីខណ្ឌរដ្ឋបាលជលផល ក្រុមស្ថាបនិកត្រូវ៖

- ការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃការបង្កើតសហគមន៍នេសាទ ដើម្បីឱ្យចូលជាសមាជិកសហគមន៍នេសាទ (យ៉ាងហោចណាស់៥០%នៃចំនួនគ្រួសារអ្នកនេសាទសរុបនៅកន្លែងនោះ)
- ចុះបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តចូលរួមជាសមាជិកសហគមន៍នេសាទ
- រៀបចំត្រៀមបេក្ខភាពឈរឈ្មោះបោះឆ្នោតជាគណៈកម្មការសហគមន៍នេសាទ (មិនមានការណែនាំជាក់លាក់អំពីការជូនដំណឹងទេ តែជាធម្មតាតែងមានកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ) អ្នកសម្របសម្រួលត្រូវធានាថាសមាជិកគ្រប់រូបបានដឹង និងមានឱកាសឈរឈ្មោះឱ្យគេបោះឆ្នោត។



## ៥.៣ ជំហានទី៣៖ ការចុះឈ្មោះសមាជិកសហគមន៍នេសាទ (ត)

- រៀបចំដំណើរការមហាសន្និបាតលើកដំបូង ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- ធ្វើលិខិតអញ្ជើញចូលរួមមហាសន្និបាត
- រៀបចំអង្គប្រជុំផ្សេងៗពាក់ព័ន្ធនឹងការត្រៀមធ្វើមហាសន្និបាត
- រៀបចំសេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដោយមានការពិគ្រោះយោបល់។



## ៥.៤ ជំហានទី៤÷ ការបង្កើតចក្ខុវិស័យ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

- **ចក្ខុវិស័យ** ជាការរៀបរាប់អំពីស្ថានភាព ដែលសមាជិកសហគមន៍នេសាទ ចង់បាននាពេលអនាគត (លទ្ធផលរយៈពេលវែង)។
- **លក្ខន្តិកៈ** ជានីតិវិធីរដ្ឋបាល កំណត់ពី របៀបសហគមន៍នេសាទដែលត្រូវបង្កើតឡើង និងដំណើរការរបស់វា (ការកត់ត្រា ការបោះឆ្នោតគណៈកម្មការសហគមន៍នេសាទ)។
- **បទបញ្ជាផ្ទៃក្នុង** ជាការរៀបរាប់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក និងការងាររបស់សហគមន៍នេសាទ (ដូចជាៈ កិច្ចប្រជុំជាដើម)។



## ៥.៥ ជំហានទី៥÷ មហាសន្និបាតលើកដំបូងជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

មហាសន្និបាតរបស់សហគមន៍នេសាទគឺជាអង្គប្រជុំកំពូលដើម្បីអនុម័ត និងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងនាមសហគមន៍នេសាទ។

មហាសន្និបាតលើកដំបូងត្រូវបានរៀបចំឡើងដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ និងអនុម័តទៅលើកិច្ចការសំខាន់ៗដូចជា៖

- សមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- គណៈកម្មការរៀបចំបោះឆ្នោត
- ចំនួនគណៈកម្មការ
- សមាសភាពឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទ។



## តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ

- សមាជិកសហគមន៍នេសាទ ត្រូវចូលរួមបោះឆ្នោតជ្រើសរើសគណៈកម្មការដើម្បីឱ្យទទួលបន្ទុកគ្រប់គ្រងសហគមន៍នេសាទ។

- គណៈកម្មការសហគមន៍នេសាទមានសិទ្ធិដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទ។

- គណៈកម្មការសហគមន៍នេសាទកើតឡើងតាមរយៈការបោះឆ្នោត។

- សមាជិកម្នាក់ៗដែលមានសញ្ជាតិខ្មែរពីកំណើតអាចជាឈរឈ្មោះជាបេក្ខជនគណៈកម្មការសហគមន៍នេសាទបាន។

- គណៈកម្មការសហគមន៍នេសាទមានអាណត្តិការងាររយៈពេល៥ឆ្នាំ។



## ៥.៦ ជំហានទី៦៖ ការកំណត់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍

ការធ្វើផែនទីកន្លែងនេសាទសហគមន៍ ដើម្បីកំណត់ច្បាស់ អំពីដែននេសាទ ដែលត្រូវគ្រប់គ្រង និងស្ថិតក្នុងការអនុវត្តនៃបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ។



## ៥.៧ ជំហានទី៧៖ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គឺជាកិច្ចព្រមព្រៀង ជាផ្លូវការរវាងសហគមន៍នេសាទ និងរដ្ឋបាលជលផលដែលទទួលស្គាល់ និងជានាសិទ្ធិរបស់សហគមន៍នេសាទចំពោះកន្លែងនេសាទសហគមន៍ ដែលបានធ្វើផែនទី។



## ៥.៨ ជំហានទី៨÷ ការចុះបញ្ជីនិងការទទួលស្គាល់សហគមន៍នេសាទ

ក្រោយពីចុះហត្ថលេខា លើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ នាយខណ្ឌរដ្ឋបាលជលផលរាជធានី ខេត្ត ត្រូវធ្វើសំណើទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះបញ្ជី និងចេញប្រកាសទទួលស្គាល់ជាផ្លូវការ។



# ៥.៩ ជំហានទី៩៖ ការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក្រោយពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គណៈកម្មការសហគមន៍ត្រូវរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវមានចំណុចសំខាន់ៗដូចជា៖

- វិធានការការគ្រប់គ្រងធនធានជលផល
- ការគ្រប់គ្រងវិវាទក្នុងសហគមន៍
- ការគោរពច្បាប់និងការពង្រឹងការអនុវត្តច្បាប់
- ការរៀបរាប់លម្អិតអំពីផែនការសកម្មភាព ការត្រួតពិនិត្យ និងវាយតម្លៃ។



# ៦. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គឺជាឯកសារដែលរៀបចំដោយសហគមន៍នេសាទ និងចុះហត្ថលេខាយល់ព្រម ដោយរដ្ឋបាលជលផល។

ខ្លឹមសារនៃផែនការកំណត់ការគ្រប់គ្រងធនធានជលផល និងសកម្មភាពមួយចំនួន។ វិធានការផ្នែកគ្រប់គ្រងរួមមាន៖

- បរិមាណផលចាប់ និងការត្រួតពិនិត្យចំនួនអ្នកនេសាទ និងឧបករណ៍នេសាទ
- វិធានការទប់ស្កាត់ឧបករណ៍ហាមឃាត់ (ឧទា. ប្រភេទ ប្រវែង ទំហំ)
- ការត្រួតពិនិត្យដែននេសាទ (ឧទា. កន្លែងអភិរក្ស និងតំបន់ការពារ)



## ៦. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ (ត)

- ត្រួតពិនិត្យពេលវេលា (ឧទា. រដូវបើក និងបិទនេសាទ)
- ការត្រួតពិនិត្យ ការចេញចូលនេសាទ (ឧទា. អនុញ្ញាតឱ្យចូល ឬហាមចូលនេសាទ)
- វិធានការការពារ និងកែលម្អជម្រកត្រី (ឧទា. ការពារជម្រកពងកូន)។

